# សេចក្តីសង្ខេប

x x ' y y

## ១.  ថវិកាដែលបានប្រើប្រាស់នៅក្នុងត្រីមាសទី៣  :

នៅក្នុងត្រីមាសទី៣ឆ្នាំ២០០៥នេះ មជ្ឈមណ្ឌលជាតិនិងខេត្ត-ក្រុងបានប្រើប្រាស់ថវិកាដែលបានអនុម័តហើយ អស់៨១%  ក្រោមគំរោង DFID, គំរោងមូលនិធិសកល (GFATM )អស់ ៨៣%, គំរោង EU/ITM អស់ ១៤០%, គំរោង CDC អស់ ៦៣%, និង គំរោង FHI អស់ ៧២% ដើម្បីគាំទ្រការអនុវត្តសកម្មភាពនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលសរុបថវិកាអស់ ៨២២,២១៧ ដុល្លាអាមេរិក ។

**តារាង   សង្ខេបថវិកាចំណាយក្នុងត្រីមាសទី៣**

| ប្រភពថវិកា | ផែនការត្រីមាសទី៣ | ថវិកាចំណាយ | % |
|---|---|---|---|
| DFID | 870,358 | 447,497 | 81% |
| EU/ITM | 80,829 | 113,313 | 140% |
| GFATM | 180,869 | 150,108 | 83% |
| CDC | 116,234 | 73,313 | 63% |
| FHI | 52,325 | 37,987 | 72% |
| **សរុប** | **1,300,615** | **822,217** | **63%** |

នៅថ្នាក់ជាតិ ថវិកាដែលបានប្រើប្រាស់ ៥៥៧,៥៨២ គឺប្រហែល៥៦% នៃគំរោងផែនការ ។

នៅថ្នាក់ខេត្ត : ខេត្ត-ក្រុងចំនួន២៤បានចំណាយថវិកាអស់ ២៦៤,២១៥ដុល្លា គឺប្រហែល ៨៥% នៃថវិកា ដែលបានអនុម័តហើយ ដើម្បីអនុវត្តសកម្មភាពបង្ការនិងទប់ស្កាត់ ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ដូចជា ការអប់រំផ្សព្វផ្សាយតាមរយៈវិទ្យុទូរទស្សន៍ និងការរៀបចំយុទ្ធនាការឃោសនាផ្សព្វផ្សាយក្នុង ឱកាសបុណ្យជាតិសំខាន់ៗ កម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ការងារគ្រប់គ្រង និងព្យាបាលជំងឺកាមរោគ សំរាប់ប្រជាជនទូទៅនៅតាមមណ្ឌលសុខភាព ការងារគ្រប់គ្រងនិងព្យាបាលជំងឺ កាមរោគ សំរាប់នារីរកស៊ីផ្លូវភេទ នៅគ្លីនិកកាមរោគទាំង ៣០, កម្មវិធីថែទាំបន្តដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ។

ខេត្តដែលប្រើប្រាស់ថវិកានៅក្រោមគំរោង DFID អស់៨៨%, ខេត្តបន្ទាយមានជ័យ ដែលប្រើប្រាស់ថវិកា របស់អង្គការ CDC អស់ ៨៥%, ខេត្តចំនួន៦ ដែលប្រើប្រាស់ថវិកាអស់ ៩២% ក្រោមគំរោងមូលនិធិសកល (GFATM) ស្រុកប្រតិបត្តិចំនួន៣ នៃខេត្ត២ (តាកែវ និងពោធិសាត់) ដែលប្រើប្រាស់ថវិកាអស់ ៥២% ក្រោម គំរោង EU/ITM ហើយក្នុងនោះក៏មានខេត្តចំនួន១៧ដែរ ដែលឧបត្ថម្ភដោយអង្គការ FHI លើសកម្មភាពប្រជុំអ្នក

អប់រំបន្តនៃក្រុមនារីរកស៊ីផ្លូវភេទ, ម្ចាស់សេវាបំរើផ្លូវភេទ និងកំសាន្តសប្បាយ និងសកម្មភាពមួយចំនួនទៀតនៅក្នុងការថែទាំ និងគ្រប់គ្រងជំងឺកាមរោគ បានចំណាយអស់ថវិកា ៧២% នៃថវិកា ដែលបានអនុមត័ហើយ ។

## ២. សកម្មភាពនៅថ្នាក់ជាតិ

យោងទៅតាមគំរោងផែនការសកម្មភាពប្រចាំត្រីមាសទី២ឆ្នាំ២០០៥ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានពង្រឹងនិងពង្រីកនូវសកម្មភាពមួយចំនួនដូចជាៈ

### ១. ការអប់រំផ្សព្វផ្សាយ កម្មវិធីអប់រំផ្ទាល់ និងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%:

ដើម្បីពង្រឹងការអនុវត្តន៏កម្មវិធីអប់រំផ្ទាល់នៅតាមបណ្តាថ្នាក់ខេត្ត-ក្រុង មន្ត្រីផ្នែក BCC ចូលរួមក្នុងកិច្ចប្រជុំសំរបសំរួល ជាមួយម្ចាស់សេវា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ក្នុងការអនុវត្តកម្មវិធី នៅខេត្ត ក្រចេះ កំពត កំពង់ធំ បាត់ដំបង ក្រុងប៉ៃលិន កំពង់ស្ពឺ ដែលឧបត្ថម្ភដោយ អង្គការ FHI ។

រៀបចំកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍ ស្តីពីការអនុវត្តន៏កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១00% នៅក្រុងព្រះសីហនុ ដែលមានអ្នកចូលរួមមកពី គណៈកម្មាការតាមដាន និងវាយតំលៃ និង ក្រុមការងារ ១០០% ប្រធានកម្មវិធីអេដស៍ មកពី ២២ ខេត្ត-ក្រុង ។

មន្ត្រីផ្នែកនេះ បានចុះអភិបាលការងារលើកម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ និងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% ការបែងចែក និងការប្រើប្រាស់សំភារៈអប់រំ នៅតាមបណ្តាខេត្តមួយ ចំនួនដូចជាៈ ខេត្តកំពង់ចាម ក្រចេះ កំពង់ស្ពឺ ក្រុងព្រះសីហនុ តាកែវ កំពត កែប បន្ទាយមានជ័យ ព្រះវិហារ កំពង់ធំ សៀមរាប កណ្តាល រាជធានីភ្នំពេញ ព្រៃវែង ស្វាយរៀង កោះកុង បាត់ដំបង ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី និងឧត្តរមានជ័យ ដើម្បីធ្វើឱ្យការអនុវត្តកម្មវិធីនេះមានដំណើរការ កាន់តែល្អប្រសើរឡើង ។

ផ្នែកនេះបានចំណាយថវិកា អស់៧៩% នៃគំរោងផែនការប្រចាំត្រីមាស ។

### ២. កម្មវិធីថែទាំជំងឺកាមរោគ

ដើម្បីឱ្យការអនុវត្តកម្មវិធីនេះកាន់តែមានភាពប្រសើរ មន្ត្រីផ្នែកជំងឺកាមរោគ បានរៀបចំកិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេស ដើម្បីរៀបចំកែលំអនូវគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រង និងថែទាំ ជំងឺកាមរោគ សំរាប់ប្រជាជនទូទៅ និងរៀបចំធ្វើការបង្កើតប្រព័ន្ធពិនិត្យគុណភាពសំរាប់មន្ទីរ ពិសោធន៍, STI symposium ។

មន្ត្រីផ្នែកនេះ បានចូលរួមជាគ្រូសំរបសំរួលក្នុងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងថែទាំជំងឺកាម រោគជាច្រើនវគ្គដូចជា វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងនិងថែទាំជំងឺកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ដល់គ្លីនិកឯកជន មកពីខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តពោធិសាត់ រៀបចំដោយអង្គការ PSI វគ្គបណ្តុះបណ្តាល

បំប៉ន ស្តីពីការគ្រប់គ្រង និងថែទាំជំងឺកាមរោគ ដល់មន្ត្រីគ្លីនិកកាមរោគ នៅខេត្តកំពត កំពង់ស្ពឺ ដែលឧបត្ថមដោយអង្គការ សុខភាពគ្រួសារអន្តរជាតិ ។

ផ្នែកនេះក៏បានចុះអភិបាល ការងារនៅតាម គ្លីនិកកាមរោគ និងមណ្ឌលសុខភាព ដែលមានសេវាថែទាំជំងឺកាមរោគ នៅតាមបណ្តាខេត្ត មួយចំនួនដូចជា: កំពង់ចាម ក្រចេះ កំពង់ស្ពឺ ក្រុងព្រះសីហនុ តាកែវ កំពត កែប បន្ទាយមានជ័យ ព្រះវិហារ កំពង់ធំ សៀមរាប ឧត្តរមានជ័យ ព្រៃវែង ស្វាយរៀង កោះកុង ភ្នំពេញ (គ្លីនិកដូនពេញ សម្តេចឪ ទួលស្វាយព្រៃ ទួលគោក )ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី ។

ផ្នែកនេះបានចំណាយថវិកា អស់៤៥% នៃគំរោងផែនការប្រចាំត្រីមាស ។

**៣. កម្មវិធីថែទាំអ្នកជំងឺអេដស៍បន្ត**

បញ្ចប់វគ្គបណ្តុះបណ្តាលរយៈពេលវែង ស្តីពីការថែទាំនិងព្យាបាលអ្នកជំងឺអេដស៍ដោយឱសថឱកាសនិយម និងឱសថប្រឆាំងនឹងមេរោគអេដស៍ ដល់ក្រុមគ្រូពេទ្យ ជំនាន់ទី២ ចំនួន២៨ នាក់ មកពីមន្ទីរពេទ្យ នៅខេត្តបាត់ដំបង, ខេត្តកំពង់ចាម, សៀមរាប, តាកែវ, កោះកុង, ពោធិសាត់, ក្រុងព្រះសីហនុ, អ្នកលឿង, ស្វាយរៀង, បន្ទាយមានជ័យ កំពង់ត្រាច កណ្តាល មន្ទីរពេទ្យកាល់ម៉ែត មណ្ឌលនៃក្តីសង្ឃឹម និងគ្លីនិកសុខភាពសង្គម /មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

រៀបចំវគ្គសិក្ខាសាលា ស្តីពីការផ្តល់ប្រឹក្សាអំពីមេរោគអេដស៍ និងជំងឺអេដស៍ ចំនួន៣វគ្គ ដល់មន្ត្រី ផ្តល់ប្រឹក្សា មកពីខេត្ត ខេត្តកំពត សៀមរាប បាត់ដំបង, កំពង់ចាម, តាកែវ, កោះកុង, ពោធិសាត់, ក្រុងព្រះសីហនុ, ព្រៃវែង, ស្វាយរៀង, បន្ទាយមានជ័យ, កណ្តាល, ភ្នំពេញ, កំពង់ឆ្នាំង, កំពង់ស្ពឺ, ឧត្តរមានជ័យ, ព្រះវិហារ, ស្ទឹងត្រែង, ក្រចេះ ។

រៀបចំវគ្គសិក្ខាសាលា ស្តីពីការគ្រប់គ្រងទិន្នន័យសំរាប់មណ្ឌលផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមមេរោគអេដស៍ និងជំងឺអេដស៍ ចំនួន១វគ្គ ដែលមានអ្នកចូលរួម១៨នាក់ មកពីខេត្តកំពត កំពង់ចាម, តាកែវ, ក្រុងព្រះសីហនុ, ព្រៃវែង, ស្វាយរៀង, កណ្តាល, ភ្នំពេញ, កំពង់ឆ្នាំង, កំពង់ស្ពឺ, ស្ទឹងត្រែង, កោះកុង ។

មន្ត្រីផ្នែកនេះ ក៏បានចុះអភិបាល និងផ្តល់ជំនួយបច្ចេកទេសលើការងារផ្តល់ប្រឹក្សា ធ្វើតេស្តឈាម ការថែទាំអ្នកជំងឺអេដស៍តាមផ្ទះ ការថែទាំនៅក្នុងមន្ទីរពេទ្យ និងការថែទាំបន្ត នៅតាមបណ្តាខេត្ត មួយចំនួនដូចជា: កណ្តាល កំពង់ចាម (ស្រុកប្រតិបត្តិក្រូចឆ្មារ, មេមត់ និងចំការលើ)ក្រចេះ ស្ទឹងត្រែង តាកែវ (ស្រុកប្រតិបត្តិគីរីវង្ស និងអង្គរកា) កំពត ព្រះវិហារ កំពង់ធំ សៀមរាប ភ្នំពេញ រតនគីរី ស្វាយរៀង កោះកុង និងព្រៃវែង ។

ផ្នែកនេះបានចំណាយថវិកា អស់៤៤% នៃគំរោងផែនការប្រចាំត្រីមាស ។

**៤. ផ្នែកអង្កេតតាមដាន និង ស្រាវជ្រាវ**

ចុះប្រមូលទិន្នន័យ ស្តីពីការអង្កេតតាមដានរកអត្រា ប្រេវ៉ាឡង់ជំងឺកាមរោគឆ្នាំ២០០៤ លើក្រុមប្រឈមមុខខ្ពស់ ដូចជា នារីរកស៊ីផ្លូវភេទដោយផ្ទាល់ ដោយប្រយោល បុរសរួមភេទជាមួយបុរស និងប៉ូលីស នៅខេត្តកោះកុង និងក្រុងព្រះសីហនុ ។

ចុះប្រមូលទិន្នន័យ ស្តីពីការអង្កេតអកម នៅខេត្តសៀមរាប បន្ទាយមានជ័យ កំពត តាកែវ ក្រុងព្រះសីហនុ ព្រះវិហារ និងខេត្តកោះកុង ។

ផ្នែកនេះបានចំណាយថវិកាអស់២២% នៃគំរោងផែនការប្រចាំត្រីមាស ។

**៥. ការងារគ្រប់គ្រង សំរបសំរួល និង ផែនការ**

រៀបចំកិច្ចប្រជុំសំរបសំរួល ដែលមានការចូលរួមពី២៤ខេត្ត-ក្រុង អង្គការជាដៃគូ និងអង្គភាពផ្សេងៗ ដូចជា មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក នាយកដ្ឋាននានានៃក្រសួងសុខាភិបាល ។

រៀបចំវគ្គសិក្ខាសាលា ស្តីពីការរៀបចំផែនការ ក្រោមគំរោងមូលនិធិសកលវគ្គទី២ នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម ដោយមានការចូលរួមពីប្រធានមន្ទីសុខាភិបាល ប្រធានកមវិធីអេដស៍ និងគណនេយ្យគំរោងមកពីខេត្ត-ក្រុងទាំ៦និងផ្នែកផ្សេងៗនៃមជ្ឈមណ្ឌលជាតិ ។

ចងក្រងនូវគំរោងផែនការសកមភាពគ្រប់ជ្រុងជ្រោយប្រចាំឆ្នាំ២០០៥,ត្រីមាសទី៣ របស់មជ្ឈមណ្ឌលជាតិ និងខេត្តក្រុងទាំង ២៤ និង របាយការណ៍ ត្រីមាស ទី២ ជាភាសាខ្មែរ និងអង់គ្លេស និងធ្វើការបែងចែកដល់ ម្ចាស់ជំនួយ មន្ទីរសុខាភិបាលខេត្ត និងស្ថាប័ន អង្គការផ្សេងៗដែល ពាក់ព័ន្ធ ។

ដើម្បីពង្រឹងការអនុវត្តសកមភាពនូវថ្នាក់ខេត្ត មន្ត្រីផ្នែកតាមដាន របាយការណ៍ និងវាយតំលៃ, ផ្នែកផែនការ និងផ្នែកហិរញ្ញកិច្ច បានចុះធ្វើការអភិបាល នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួន នៅខេត្ត កំពង់ចាម ប៉ៃលិន ពោធិសាត់ បាត់ដំបង កំពត កែប មណ្ឌលគីរី តាកែវ ។

ផ្នែកនេះបានចំណាយថវិកា អស់៨០% នៃគំរោងផែនការប្រចាំត្រីមាស ។

ភ្នំពេញ, ថ្ងៃទី វិច្ឆិកា ឆ្នាំ ២០០៥

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង**
**ជំងឺអេដស៍ សើស្បែក និងកាមរោគ**

ផ្នែកតាមដានត្រួតពិនិត្យ
របាយការណ៍ និងវាយតំលៃ

**វេជ្ជ. ម៉ុត សុគន្ធារី**

# មាតិកា


១. សេចក្តីផ្តើម ១

២. ការអនុវត្តន៍កម្មវិធី ២

១. កញ្ចប់សំរាប់បង្ការ ២

១.១ កម្មវិធីអប់រំ ពត៌មាន ផ្សព្វផ្សាយមហាជន ២

១.២ កម្មវិធីអប់រំផ្ទាល់ ៤

១.៣ កម្មវិធិប្រើប្រាស់ស្រោមអនាម័យ១០០% ៧

១.៤ កម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគ ៨

២. កញ្ចប់សំរាប់ថែទាំ និងព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ១៣

២.១ ការថែទាំអ្នកជំងឺអេដស៍នៅក្នុងមន្ទីរពេទ្យ ១៣

២.២ ការថែទាំអ្នកជំងឺអេដស៍នៅតាមផ្ទះ និងនៅក្នុងសហគមន៍ ១៦

២.៣ ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម រកមេរោគអេដស៍ ដោយសគ្រ័ចិត្ត និងរក្សាការសំងាត់ ១៧

៣. កញ្ចប់អង្កេត និងស្រាវជ្រាវ ១៨

៣.១ ការអង្កេតតាមដាន ១៨

៣.២ ការស្រាវជ្រាវ ១៩

៤. កញ្ចប់គ្រប់គ្រង ២០

៤.១ ផែនការ គ្រប់គ្រង និងសំរបសំរួល ២០

៤.២ ការតាមដានត្រួតពិនិត្យ របាយការណ៍ និងវាយតំលៃកម្មវិធី ២១

## ឧបសម្ព័ន្ធ ៖

## ឧបសម្ព័ន្ធទី១ ៖ តារាងទិន្ន័យ

តារាងទី១ ៖ សង្ខេបថវិកាចំណាយ របស់មជ្ឈមណ្ឌលជាតិ

តារាង ទី២ ៖ សង្ខេបថវិកាចំណាយ របស់ខេត្ត-ក្រុង

តារាង ទី៣ ៖ ទិន្ន័យអ្នកជំងឺអេដស៍ទទួលឱសថពន្យារជីវិត

តារាង ទី៤ ៖ ទិន្ន័យថែទាំអ្នកជំងឺអេដស៍នៅតាមផ្ទះនិងនៅក្នុងសហគមន៍

តារាង ទី៥ ៖ ទិន្ន័យផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សា ការសំងាត់

**ឧបសម្ព័ន្ធទី២** ៖ របាយការណ៍សិក្ខាសាលា វគ្គបណ្តុះបណ្តាល

**ឧបសម្ព័ន្ធទី៣** ៖ របាយការណ៍កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេស

# របាយការណ៍សកម្មភាពប្រយុទ្ធនឹងជម្ងឺអេដស៍_កាមរោគ
# ប្រចាំត្រីមាសទី៣ ឆ្នាំ ២០០៥

x x Ò y y

## ១. សេចក្តីផ្តើម :

គំរោងផែនការប្រចាំឆ្នាំ ២០០៥ រាប់បញ្ចូលទាំងប្រាក់ឧបត្ថម្ភ (PBSI) ផងនោះ មានថវិការសរុបទាំងអស់ចំនួន ១៧,៨៤៨,៤៩១ ដុល្លា , ក្នុងនោះមានថវិកាប្រហែល៦០% គ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិ, និង៤០% គ្រប់គ្រងដោយ អង្គការជាដៃគូការងារ ។

នៅក្នុងត្រីមាសទី៣នេះ ថវិកាដែលបានចំណាយមានចំនួន **៨២២,២១៧** ដុល្លា គឺ១០%នៃគំរោងផែនការប្រចាំឆ្នាំ, ៦៣% នៃគំរោងផែនការប្រចាំត្រីមាស ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិ ។

**តារាងទី១: សង្ខេបថវិកាចំណាយក្នុងត្រីមាសទី៣**

| ប្រភពថវិកា | ផែនការត្រីមាសទី១ | ថវិកាចំណាយ | % |
|---|---|---|---|
| DFID | 870,358 | 447,497 | 81% |
| EU / ITM | 80,829 | 113,313 | 140% |
| GFATM | 180,869 | 150,108 | 83% |
| CDC | 116,234 | 73,313 | 63% |
| FHI | 52,325 | 37,987 | 72% |
| **សរុប** | **1,300,615** | **822,217** | **63%** |

នៅក្នុងត្រីមាសនេះដែរ ការចំណាយថវិកានៅថ្នាក់ខេត្ត មានភាពខ្ពស់ជាងនៅថ្នាក់ជាតិ ។

**តារាងទី២: សង្ខេបថវិកាចំណាយនៅថ្នាក់ខេត្ត ក្នុងត្រីមាសទី៣**

| | Province | Total Expenditure in Q3 | | | | | |
|---|---|---|---|---|---|---|---|
| | | DFID | GFATM | FHI | CDC | EU-ITM | Total |
| 1 | BMC | | | $ 1,077 | $ 71,773 | | $ 72,850 |
| 2 | BTB | $ 5,084 | | $ - | | | $ 5,084 |
| 3 | KCM | $ 3,955 | $ 7,826 | $ 2365 | | | $ 14,146 |
| 4 | KCN | $ 6,333 | | $ 1,211 | | | $ 7,544 |
| 5 | KDL | $ 10,269 | | $ 1,081 | | | $ 11,350 |
| 6 | KEP | $ 3,012 | | | | | $ 3,012 |
| 7 | KPT | $ 8,404 | | $ 1,115 | | | $ 9,519 |
| 8 | KTM | $ 7,003 | | $ 1,844 | | | $ 8,847 |
| 9 | KRT | $ 7,653 | | $ 817 | | | $ 8,470 |
| 10 | KSP | $ 9,002 | | $ 999 | | | $ 10,001 |
| 11 | KHK | $ 6,692 | | $ - | | | $ 6,692 |
| 12 | OMC | $ 4,973 | | | | | $ 4,973 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 13 | MDK | $ 2,899 | | | | | $ 2,899 |
| 14 | PLN | $ 2,214 | $ 3,115 | $ 1,144 | | | $ 6,473 |
| 15 | PNP | $ 1,885 | $ 3,002 | $ - | | | $ 4,887 |
| 16 | PST | $ 2,108 | $ 7,475 | $ 1,052 | | $ 384 | $ 10,635 |
| 17 | PVG | $ 23,434 | | | | | $ 23,434 |
| 18 | PVH | $ 3,036 | | | | | $ 3,036 |
| 19 | RTK | $ 4,744 | | | | | $ 4,744 |
| 20 | SRP | $ 9,896 | | $ 2,106 | | | $ 12,002 |
| 21 | SHV | $ 2,963 | $ 4,039 | $ - | | | $ 7,002 |
| 22 | STG | $ 4,590 | | $ - | | | $ 4,590 |
| 23 | SVR | $ 13,225 | | | | | $ 13,225 |
| 24 | TKV | $ 3,374 | $ 5,334 | $ 514 | | $ 3,804 | $ 9,222 |
| | **សរុប** | **$ 146,747** | **$ 30,791** | **$ 15,325** | **$ 71,773** | **$ 4,188** | **$ 264,635** |

នៅក្នុងត្រីមាសទី៣នេះ ខេត្ត-ក្រុងចំនួន២៤បានចំណាយថវិកាអស់ **២៦៤,២១៥** ដុល្លា គឺប្រហែល ៨៥% នៃថវិកាដែលបានអនុម័តហើយដើម្បីអនុវត្តសកម្មភាពបង្ការនិងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ដូចជា ការអប់រំផ្សព្វផ្សាយតាមរយៈវិទ្យុទូរទស្សន៍ និងការរៀបចំយុទ្ធនាការឃោសនាផ្សព្វផ្សាយក្នុង ឱកាសបុណ្យជាតិសំខាន់ៗ កម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ការងារគ្រប់គ្រងនិងព្យាបាលជំងឺកាមរោគ សំរាប់ប្រជាជនទូទៅនៅតាមមណ្ឌលសុខភាព ការងារគ្រប់គ្រងនិងព្យាបាលជំងឺកាមរោគ សំរាប់នារីរកស៊ីផ្លូវភេទ នៅគ្លីនិកកាមរោគទាំង ៣០, កម្មវិធីថែទាំបន្តដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នក ជំងឺអេដស៍ ។

ខេត្តដែលប្រើប្រាស់ថវិកានៅក្រោមគំរោង DFID អស់៨៨%, ខេត្តបន្ទាយមានជ័យ ដែលប្រើប្រាស់ថវិការបស់អង្គការ CDC អស់ ៨៥%, ខេត្តចំនួន៦ ដែលប្រើប្រាស់ថវិកាអស់ ៩២% ក្រោមគំរោងមូលនិធិសកល (GFATM) ស្រុកប្រតិបត្តិចំនួន៣ នៃខេត្ត២ (តាកែវ និងពោធិសាត់) ដែលប្រើប្រាស់ថវិកាអស់ ៩២% ក្រោម គំរោង EU/ITM ហើយក្នុងនោះក៏មានខេត្តចំនួន១៧ដែរ ដែលឧបត្ថម្ភដោយអង្គការ FHI លើសកម្មភាពប្រជុំអ្នក អប់រំបន្តនៃក្រុមនារីរកស៊ីផ្លូវភេទ, ម្ចាស់សេវាបំរើផ្លូវភេទ និងកំសាន្តសប្បាយ និងសកម្មភាពមួយចំនួនទៀតនៅក្នុងការថែទាំ និងគ្រប់គ្រងជំងឺកាមរោគ បានចំណាយអស់ថវិកា ៧២% នៃថវិកា ដែលបានអនុម័តហើយ ។

## ២. ការអនុវត្តន៍សកម្មភាព :

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃគំរោងផែនការយុទ្ធសាស្ត្រ ដើម្បីបង្ការការរាលដាលជំងឺអេដស៍ជំងឺកាមរោគ និងថែទាំអ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍ ទាំងថ្នាក់ជាតិនិងថ្នាក់ខេត្តបានអនុវត្តសកម្មភាព ដូចខាងក្រោមនេះ:

### ១. កញ្ចប់សំរាប់បង្ការ :

#### ១.១ កម្មវិធីអប់រំ ពត៌មាន ផ្សព្វផ្សាយមហាជន :

#### ក. ការផលិត និងចែកចាយសំភារៈអប់រំផ្សព្វផ្សាយ :

**សកម្មភាពនៅថ្នាក់ជាតិ:**

- ដើម្បីឆ្លើយតបទៅនឹងតំរូវការសំភារៈអប់រំស្តីពីជំងឺអេដស៍/កាមរោគ សំរាប់ប្រើប្រាស់ក្នុងសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិបានផលិតសំភារៈមួយចំនួន សំរាប់បែងចែកដល់បណ្តា ខេត្ត-ក្រុង ដើម្បីធ្វើយុទ្ធនាការអបរំផ្សព្វផ្សាយនៅក្នុងឱកាសបុណ្យអុំទូក ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ដូចជា:
  - ខិត្តប័ណ្ណ : ចំនួន ២០០,០០០ សន្លឹក
  - ផ្ទាំងរូបភាពធំ : ៤ប្រភេទ ចំនួន ៤០,០០០ សន្លឹក
  - មួក : ចំនួន ១១,៤០០០
  - អាវយឺត : ចំនួន ១១,៤០០០

និងបោះពុម្ពសៀវភៅមួយចំនួនទៀតដូចជា:

  - គោលការណ៍ណែនាំស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើមនុស្សពេញវ័យ ចំនួន ១០០០ក្បាល ។
  - សេចក្តីណែនាំសំរាប់បង្កើតមណ្ឌលផ្តល់ប្រឹកសា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ចំនួន ១០០០ក្បាល ។
  - គោលការណ៍ណែនាំ ស្តីពីការថែទាំអ្នកជំងឺអេដស៍ តាមផ្ទះ និងក្នុងសហគមន៍ ចំនួន ១០០០ក្បាល
  - សៀវភៅបណ្តុះបណ្តាល ស្តីពីការផ្តល់ប្រឹក្សា ក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ សំរាប់គិលានុប្បដ្ឋាក-យិកា ចំនួន ១០០០ក្បាល ។
- ចូលរួមប្រជុំដើម្បីបង្កើតសំភារៈវីដេអូ ដែលរួមមានស្ពុតវីដេអូ និងវិទ្យុ ជាមួយក្រុមការងារបច្ចេកទេស ។
- ចូលរួមជាគ្រូសំរបសំរួល វគ្គបណ្តុះបណ្តាលស្តីពី ចំណេះដឹងជាមូលដ្ឋាននៃមេរោគអេដស៍ ជំងឺអេដស៍ និងកាមរោគ ក្នុងកម្មវិធីកាត់បន្ថយការចំលងមេរោគអេដស៍ដល់មន្ត្រីមណ្ឌលសុខភាព នៅខេត្តពោធិសាត់ និងខេត្តបន្ទាយមានជ័យ ។
- ចុះធ្វើតេស្តសាកល្បង លើសារ និងរូបភាព នៃខិត្តបណ្ណ័ និងរូបផ្ទាំងធំ នៅរាជធានីភ្នំពេញ កណ្តាល និងខេត្តកំពង់ស្ពឺ ។

**សកម្មភាពនៅថ្នាក់ខេត្ត :**

- ធ្វើការផ្សព្វផ្សាយពត៌មាន ស្តីពីការអប់រំ និងថែទាំជម្ងឺអេដស៍ និងកាមរោគ តាមរយៈទូរទស្សន៍ខ្សែកាប, វិទ្យុខេត្ត តាមកាណូតលឿន នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួន ដូចជា ខេត្តឧត្តរមានជ័យ ប៉ៃលិន ព្រះវិហារ រតនគីរី កែប បន្ទាយមានជ័យ ស្ទឹងត្រែង ក្រចេះ និងកោះកុង ។

- ធ្វើការចែកចាយសំភារៈអប់រំមួយចំនួន ដល់គ្លីនិកកាមរោគខេត្ត ស្រុកប្រតិបត្តិ មណ្ឌលធ្វើតេស្តឈាម និង មន្ទីរ ឬអង្គការមួយចំនួនដែលធ្វើការងារអេដស៍នៅក្នុងខេត្ត ។
- វគ្គបណ្តុះបណ្តាល ស្តីពីចំនេះដឹងពីជំងឺអេដស៍ និងកាមរោគ ដល់មន្ត្រីសុខាភិបាលមន្ទីរពេទ្យកោះធំ និងមន្ទីរពេទ្យតាខ្មៅ ដែលឧបត្ថម្ភដោយអង្គការសុខភាពគ្រួសារអន្តរជាតិ (ខេត្តកណ្តាល) ។

## ១.២ កម្មវិធីអប់រំផ្ទាល់ :

**សកម្មភាពនៅថ្នាក់ជាតិ :**

- ដើម្បីពង្រឹងការអនុវត្តន៍កម្មវិធីអប់រំផ្ទាល់នៅតាមបណ្តាថ្នាក់ខេត្ត-ក្រុង មន្ត្រីផ្នែក BCC ចូលរួមក្នុងកិច្ចប្រជុំសំរបសំរួល ជាមួយម្ចាស់សេវា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ក្នុងការអនុវត្តកម្មវិធី នៅខេត្ត តាកែវ ដែលឧបត្ថម្ភដោយ អង្គការ FHI ។
- មន្ត្រីផ្នែកពត៌មានអប់រំ និងទំនាក់ទំនង បានចុះអភិបាលការងារលើកម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ កម្មវិធីស្រោមអនាម័យ ១០០% ការបែងចែកនិងការប្រើប្រាស់សំភារៈអប់រំ នៅតាមបណ្តាខេត្ត-ក្រុង ដូចជា ខេត្ត កំពង់ស្ពឺ ក្រុងព្រះសីហនុ កំពង់ចាម ក្រចេះ តាកែវ កំពត កែប កំពង់ធំ ព្រះវិហារ កំពង់ឆ្នាំង ពោធិសាត់ បន្ទាយមានជ័យ និងសៀមរាប ។

**សកម្មភាពនៅថ្នាក់ខេត្ត :**

- ដើម្បីគាំទ្រកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ចុះធ្វើការអប់រំដល់ក្រុមប្រឈមមុខខ្ពស់ ដូចជា នារីបំរើសេវា ផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល នៅតាមផ្ទះបន និងនៅទីកន្លែងកំសាន្តសប្បាយ ក្រុមម៉ូតូឌុប ក្រុមអ្នករត់តាក់ស៊ី ក្រុមអ្នកនេសាទ ប៉ូលីស ទាហាន កម្មករកំពង់ផែ និងកាស៊ីណូ ជាដើម ។

តារាង : ការចុះអប់រំដំនារីរកស៊ីផ្លូវភេទនៅតាមបណ្តាខេត្ត-ក្រុង នៅក្នុងត្រីមាស ២

| | ខេត្ត | ខែកក្កដា | ខែសីហា | ខែកញ្ញា | សរុប |
|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | NA | NA | NA | NA |
| 2 | បាត់ដំបង | 776 | 774 | 750 | 2300 |
| 3 | កំពង់ចាម | 507 | 594 | 580 | |
| 4 | កំពង់ឆ្នាំង | 141 | 141 | 255 | 537 |
| 5 | កំពង់ធំ | 298 | 296 | 296 | 890 |
| 6 | កណ្តាល | 127 | 127 | 111 | 366 |
| 7 | កំពង់ស្ពឺ | 165 | 167 | 179 | 511 |

| | | | | | |
|---|---|---|---|---|---|
| 8 | កំពត | NA | NA | NA | NA |
| 9 | កោះកុង | 308 | 296 | 311 | 915 |
| 10 | ក្រចេះ | 153 | 152 | 142 | 447 |
| 11 | ឧត្តរមានជ័យ | 150 | 150 | 150 | 150 |
| 12 | មណ្ឌលគីរី | 62 | 64 | 57 | 183 |
| 13 | ភ្នំពេញ | NA | NA | NA | NA |
| 14 | ប៉ៃលិន | 221 | 0 | 231 | 452 |
| 15 | ពោធិសាត់ | 137 | 132 | 151 | 420 |
| 16 | ព្រៃវែង | 152 | 171 | 126 | 449 |
| 17 | ព្រះវិហារ | NA | NA | NA | NA |
| 18 | រតនគីរី | NA | NA | NA | NA |
| 19 | សៀមរាប | 69 | 64 | 64 | 197 |
| 20 | ក្រុងព្រះសីហនុ | 361 | 363 | | |
| 21 | ស្វាយរៀង | 118 | 141 | 116 | 375 |
| 22 | ស្ទឹងត្រែង | 57 | 63 | 68 | 188 |
| 23 | តាកែវ | 256 | 256 | 256 | 768 |

- ចុះធ្វើការអប់រំប្រជាជន នៅក្នុងសហគមន៍ (ខេត្តក្រចេះ ខេត្តបន្ទាយមានជ័យ ក្រុងប៉ៃលិន ក្រុងព្រះសីហនុ និងក្រុងកែប) ។
- ប្រជុំប្រចាំខែជាមួយគណកម្មាការក្រុមប្រឹក្សា ឃុំសង្កាត់ តំណាងមកពីអង្គការ CDC និងអង្គការក្រៅរដ្ឋាភិបាល (ខេត្តបន្ទាយមានជ័យ) ។
- កិច្ចប្រជុំ រយៈពេល២ថ្ងៃ ពិនិត្យឡើងវិញនូវគំរោងផែនការយុទ្ធសាស្ត្ររបស់គណកម្មាការក្រុមប្រឹក្សាឃុំដែលមានសិក្ខាកាម២៧រូប មកពីមន្ទីរសុខាភិបាល គណកម្មាការក្រុមប្រឹក្សាឃុំ (ខេត្តបន្ទាយមានជ័យ) ។
- ប្រជុំដើម្បីរៀបចំសៀវភៅបណ្តុះបណ្តាលស្តីពីការអប់រំអំពីមេរោគអេដស៍ ជំងឺអេដស៍ និងសុខភាពបន្តពូជសំរាប់អប់រំសិស្សសាលា (ខេត្តបន្ទាយមានជ័យ) ។

ចំនួនប្រជាជន ដែលបានចុះអប់រំ នៅក្នុងត្រីមាសទី៣:

| | ខេត្ត | ខែកក្កដា | ខែសីហា | ខែកញ្ញា | សរុប |
|---|---|---|---|---|---|
| 1 | ក្រុងកែប | 228 | 176 | 187 | 591 |

| | | | | | |
|---|---|---|---|---|---|
| 2 | ក្រចេះ | 71 | 63 | 63 | 197 |
| 3 | ក្រុងព្រះសីហនុ | 114 | 122 | | |

- រៀបចំការប្រជុំក្រុមមិត្តអប់រំមិត្តនៃក្រុមនារីរកស៊ីផ្លូវភេទដោយផ្ទាល់ ២ដងក្នុងមួយត្រីមាស និងប្រជុំជាមួយម្ចាស់សេវាបំរើផ្លូវភេទ និងសេវាកំសាន្តសប្បាយនានា ក្នុងមួយត្រីមាស ប្រជុំជាមួយម្ចាស់បន រៀងរាល់ត្រីមាស ដើម្បីជំរុញការប្រើប្រាស់ស្រោមអនាម័យ១00% នៅលើក្រុមនារីរកស៊ីផ្លូវភេទ និងទទួលបាននូវ សេវាថែទាំនិងព្យាបាលជំងឺកាមរោគ ។

***Table :*** Outreach activities

| | Provinces | Peer meeting | | Owner meeting | | POT meeting | |
|---|---|---|---|---|---|---|---|
| | | # of meeting | # of participants | # of meeting | # of participants | # of meeting | # of participants |
| 1 | BMC | 1 | 155 | 1 | 50 | 0 | 0 |
| 2 | BTB | 0 | 0 | 0 | 0 | 3 | 30 |
| 3 | KCM | 4 | 162 | 2 | 119 | 3 | 33 |
| 4 | KCN | 2 | 90 | 1 | 35 | 3 | 27 |
| 5 | KTM | NA | NA | NA | NA | 1 | 10 |
| 6 | KDL | NA | NA | 1 | 54 | 3 | 32 |
| 7 | KEP | 2 | 88* | 0 | 0 | 3 | 13 |
| 8 | KSP | 2 | 66 | 1 | 45 | 3 | 30 |
| 9 | KPT | 2 | 76 | 1 | 38 | 3 | 24 |
| 10 | KHK | 2 | 50 | 1 | 25 | 2 | 20 |
| 11 | KRT | 2 | 50 | 1 | 44 | 3 | 24 |
| 12 | OMC | 0 | 0 | 1 | 28 | 1 | 8 |
| 13 | MDK | 0 | 0 | 1 | NA | 3 | 18 |
| 14 | PNP | 0 | 0 | 0 | 0 | 3 | 42 |
| 15 | PLN | 2 | 72 | 1 | 31 | 2 | 19 |
| 16 | PST | 4 | 71 | 1 | 31 | 3 | 24 |
| 17 | PVG | 2 | 65 | 3 | 63 | 1 | 11 |
| 18 | PVH | 2 | 50 | 1 | 20 | 3 | 12 |
| 19 | RTK | NA | NA | NA | NA | NA | NA |
| 20 | SRP | 4 | 115 | 2 | 50 | 3 | 36 |
| 21 | SHV | NA | NA | NA | NA | NA | NA |
| 22 | SVR | 2 | 49 | 1 | 30 | 3 | 27 |
| 23 | STG | 2 | 40 | 1 | 24 | 3 | 12 |
| 24 | TKV | 2 | 60 | 1 | 64 | 3 | 24 |

កំណត់សំគាល់ : មិត្តអប់រំមិត្តនៅក្រុងកែប គឺមិត្តអប់រំមិត្តរបស់ក្រុមនេសាទ និងប្រជាជនទូទៅ

- រៀបចំវគ្គបណ្តុះបណ្តាល បំប៉នស្តីពីចំណេះដឹងជាមូលដ្ឋាន នៃមេរោគអេដស៍ និងជំងឺអេដស៍ និងកាមរោគ ដល់ក្រុមមិត្តអប់រំមិត្ត របស់នារីរកស៊ីផ្លូវភេទ ។

| | ខេត្ត | ចំនួនសិក្ខាកាម |
|---|---|---|
| 1 | ប៉ៃលិន | 40p |
| 2 | ស្ទឹងត្រែង | 20p |
| 3 | តាកែវ | 30p |

- ចុះអភិបាលការងារអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត នៅតាមស្រុកប្រតិបត្តិ (ខេត្តស្វាយរៀង កំពង់ចាម កំពង់ធំ ឧត្តរមានជ័យ កោះកុង កែប ក្រុងព្រះសីហនុ និងពោធិសាត់) ។

## ១.៣ កម្មវិធិប្រើប្រាស់ស្រោមអនាម័យ១០០% :

**សកម្មភាពនៅថ្នាក់ជាតិ :**

- បន្តពង្រឹងគោលនយោបាយ ស្តីពីកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ក្រុមការងារស្រោមអនាម័យ, ក្រុមតាមដាន និងវាយតំលៃស្រោម អនាម័យ ។

- រៀបចំវគ្គសិក្ខាសាលា រយៈពេល៣ថ្ងៃ ស្តីពីការពិនិត្យឡើងវិញពីគោលនយោបាយកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% និងកម្មវិធីអប់រំផ្ទាល់ ដែលមានអ្នកចូលរួមពី ប្រធានកម្មវិធីអេដស៍ មកពី ១០ ខេត្ត-ក្រុង ( ខេត្តកំពង់ចាម បាត់ដំបង កណ្តាល ប៉ៃលិន ពោធិសាត់ ភ្នំពេញ ក្រុងព្រះសីហនុ តាកែវ សៀមរាប និង កោះកុង) ផ្នែកផ្សេងៗនៃមជ្ឈមណ្ឌលជាតិ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការសុខភាពគ្រួសារអន្តរជាតិ *(សូមមើលរបាយការណ៍ នៅក្នុងឧបសម្ព័ន្ធទី២)* ។

**សកម្មភាពនៅថ្នាក់ខេត្ត :**

- ពង្រឹងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% នៅគ្រប់ខេត្ត-ក្រុង ដោយរៀបចំប្រជុំក្រុមការងារ ១00% ប្រចាំសប្តាហ៏ រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាការតាមដាន និងវាយតំលៃ ។
- រៀបចំកិច្ចប្រជុំសំរបសំរួលប្រចាំត្រីមាស ដើម្បីពិនិត្យមើលសកម្មភាពឡើងវិញ ដើម្បីដោះស្រាយបញ្ហា និងលើកគំរោងផែនការសំរាប់ត្រីមាសក្រោយ ។
- ផ្គត់ផ្គង់ស្រោមអនាម័យ ដល់កម្មវិធីអប់រំផ្ទាល់ គ្លីនិកកាមរោគ និងមណ្ឌលធ្វើតេស្តឈាមជារៀងរាល់ខែ ។

***Table6*** : Summary of 100 CUP activities in 22 provinces-cities

| Provinces | # of CUGW meeting ( participants) | # of CUMEC meeting (participants) | # of Condom distributed |
|---|---|---|---|
| 1 BMC | 12 (192p) | 0 | 0 |

| | | | | |
|---|---|---|---|---|
| 2 | BTB | 12 (72p) | 3 (31p) | 15,000 |
| 3 | KCM | 12 (107p) | 3 (32p) | 30,000 |
| 4 | KCN | 12 (120p) | 3 (33p) | 5,000 |
| 5 | KTM | 12(156p) | 1 (10p) | 30,000 |
| 6 | KDL | 12 (96p) | 3 (24p) | 17280 |
| 7 | KSP | 12 (96p) | 3 (30p) | 0 |
| 8 | KPT | 12 (84p) | 3 (38p) | 0 |
| 9 | KHK | 8 (96p) | 0 | 15,000 |
| 10 | KRT | 12 (60p) | 3 (36p) | 7,500 |
| 11 | MDK | 0 | 0 | 3,000 |
| 12 | OMC | 12 (48p) | 3 (21p) | 30,000 |
| 14 | PNP | 12 (300p) | 1 (27p) | 45,000 |
| 15 | PLN | 12 (98p) | 2 (20p) | 3,600 |
| 16 | PST | 12 (180p) | 0 | 15,000 |
| 17 | PVG | 12 (166p) | 1 (12p) | 15,000 |
| 18 | PVH | 12 (48p) | 0 | 0 |
| 19 | RTK | 12 (48p) | 3 (18p) | 6,000 |
| 20 | SRP | 12 (108p) | 0 | 0 |
| 21 | SHV | NA | NA | NA |
| 22 | SVR | 12 (96p) | 0 | 0 |
| 23 | STG | 12 (84p) | 3 (18p) | 6,000 |
| 24 | TKV | 12 (72p) | 2 (14p) | 15,000 |

* **NB:**

- BMC has 4 CUWGs (Sisophon, Thmar Puok, Mongkulborei, and Ochrov)
- KCM has 3 CUWGs (Kampong Cham town, Tbong Khmum, and Memut district)
- KTM has 2 CUWGs (Kampong Thom, and Baray)
- PVG has 3 CUWGs (Kampong Leav, Prey Veng and Neak Loeung)
- PST has 3 CUWGs (Sampov Meas, Krakor, and Kravanh)
- SVR has 2 CUWGs (Svay Rieng town, and Bavet commune).
- PNP has 7 CUWGs in 7 khans

## ១.៤ ការថែទាំជំងឺកាមរោគ :

### សកម្មភាពនៅថ្នាក់ជាតិ :

#### ក. ការរៀបរៀងឯកសារ និងគោលការណ៍ណែនាំ :

ដើម្បីឱ្យការអនុវត្តកម្មវិធីនេះកាន់តែមានភាពប្រសើរ មន្ត្រីផ្នែកជំងឺកាមរោគ បានរៀបចំកិច្ចប្រជុំ ជាមួយក្រុមការងារបច្ចេកទេស:***(សូមមើលរបាយការណ៍ នៅក្នុងឧបសម្ព័ន្ធទី៣)***

- ពិនិត្យកែលំអឡើងវិញ នូវបណ្ណ័សំរាប់ស្រង់ប្រវត្តិជំងឺ (Standard Medical history Card) សំរាប់នារីរកស៊ីផ្លូវភេទ អតិថិជន បុរស និងស្ត្រីមេផ្ទះ
- HIV / AIDS Symposium and Quality Assurance for STI laboratory testing
- Presentation and discussion on Protocol for STI Management for SWs

### គ. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា និង កិច្ចប្រជុំ :

- រៀបចំវគ្គបណ្តុះបណ្តាលចំនួន២វគ្គ ស្តីពីការគ្រប់គ្រងនិងថែទាំជំងឺកាមរោគសំរាប់ស្ត្រីរកស៊ីផ្លូវភេទ ដល់មន្ត្រីគ្លីនិកកាមរោគ ចំនួន៤២នាក់ មកពីខេត្ត កំពត កំពង់ស្ពឺ កណ្តាល បាត់ដំបង ព្រៃវែង ពោធិសាត់ ឧត្តរមានជ័យ ប៉ៃលិន ក្រចេះ កំពង់ឆ្នាំង កំពង់ធំ កំពង់ចាម បន្ទាយមានជ័យ តាកែវ រតនគិរី ភ្នំពេញ គ្លីនិក MEC និងដោយអង្គការ PSI. ***(សូមមើលរបាយការណ៍ នៅក្នុងឧបសម្ព័ន្ធទី២)***
- ចូលរួមជាគ្រូសំរបសំរួល ក្នុងការចុះធ្វើកម្មសិក្សា ស្តីពីការគ្រប់គ្រងនិងថែទាំជំងឺកាមរោគ សំរាប់នារីរកស៊ីផ្លូវភេទ នៅគ្លីនិកកាមរោគទួលគោក។
- រៀបចំវគ្គបណ្តុះបណ្តាលបំប៉ន ចំនួន២វគ្គ ស្តីពីការគ្រប់គ្រងនិងថែទាំជំងឺកាមរោគដោយពឹងផ្អែកមន្ទីរពិសោធន៍ ដល់មន្ត្រីគ្លីនិកកាមរោគ ចំនួន៣៣នាក់ មកពីខេត្ត កំពត កំពង់ស្ពឺ កណ្តាល បាត់ដំបង ព្រៃវែង សៀមរាប ស្វាយរៀង ប៉ៃលិន កោះកុង បន្ទាយមានជ័យ តាកែវ និងភ្នំពេញ ។ ***(សូមមើលរបាយការណ៍ នៅក្នុងឧបសម្ព័ន្ធទី២)***
- ចូលរួមជាគ្រូសំរបសំរួលវគ្គបណ្តុះបណ្តាល ចំនួន២វគ្គ ស្តីពីការគ្រប់គ្រងនិងថែទាំជំងឺកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា សំរាប់អ្នកផ្តល់សេវាបន្ទប់ពិគ្រោះព្យាបាលជំងឺសញ្ញាព្រះអាទិត្យ រៀបចំដោយអង្គការ PSI.
- ចូលរួមជាគ្រូសំរបសំរួលវគ្គបណ្តុះបណ្តាល ចំនួន២វគ្គ ស្តីពីការគ្រប់គ្រងនិងថែទាំជំងឺកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ដល់មន្ត្រីមណ្ឌលសុខភាព នៅមន្ទីរសុខាភិបាលខេត្តបាត់ដំបងរៀបចំដោយអង្គការ RACHA និងកម្មវិធីអេដស៍ខេត្តសៀមរាប។

### ឃ. ការងារអភិបាល :

- មន្ត្រីផ្នែកប្រយុទ្ធនឹងជំងឺកាមរោគ បានចុះអភិបាលលើការងារគ្រប់គ្រង និងការផ្តល់សេវាថែទាំជំងឺកាមរោគ បណ្តាខេត្ត-ក្រុង ដូចជាខេត្ត បន្ទាយមានជ័យ (គ្លីនិកបោយប៉ែត និងសេរីសោភ័ណ្ឌ) សៀមរាប ឧត្តរមានជ័យ កំពង់ធំ ព្រះវិហារ កំពង់ស្ពឺ ក្រុងព្រះសីហនុ កំពង់ចាម ក្រចេះ តាកែវ កំពត កែប។

## គ្លីនិកជាតិសើស្បែក និងកាមរោគ

### ក. ការពិនិត្យ និងព្យាបាលជំងឺ

| Disease | Dermatology | | STD | | Surgery | | HIV Cases follow up | |
|---|---|---|---|---|---|---|---|---|
| Month | Male | Female | Male | Female | Male | Female | Male | Female |
| July | 1107 | 1516 | 59 | 66 | 7 | 10 | 2 | 2 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| August | 1995 | 2343 | 77 | 111 | 15 | 15 | 6 | 1 |
| September | 1574 | 1920 | 69 | 103 | 10 | 13 | 5 | 1 |

### ខ. មន្ទីរពិសោធន៍វេជ្ជសាស្ត្រ

**A. Serology**

| **Test** | **RPR** | | **TPPA** | | **HBs-Ag** | | **HBs-Ab** | | **HCV-Ab** | | **HIV-Ab** | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| Month | Total | + | Total | + | Total | + | Total | + | Total | + | Total | + |
| July | 111 | 0 | 42 | 4 | 83 | 9 | 80 | 26 | 79 | 6 | 217 | 20 |
| August | 124 | 9 | 55 | 9 | 77 | 14 | 76 | 32 | 75 | 2 | 171 | 25 |
| September | 111 | 1 | 38 | 3 | 65 | 0 | 64 | 27 | 65 | 3 | 131 | 14 |

**B. Bacteriology**

| **Method** | **Gram Stain** | | | | **Wet mount** | |
|---|---|---|---|---|---|---|
| Months | GNID | PMNs >10 | Yeast | # of test | Trichomonas | # of test |
| July | 4 | 53 | 11 | 80 | 1 | 69 |
| August | 4 | 38 | 10 | 57 | 0 | 43 |
| September | 6 | 28 | 12 | 48 | 0 | 32 |

### គ. ក្រុមគ្លីនិកចល័ត :

- ក្រុមចល័តដែលមានគ្រូពេទ្យម្នាក់ និងបុគ្គលិកចំនួន២រូប បានសហការជាមួយអង្គការឱសថការី គ្មានព្រំដែន ចុះធ្វើការពិនិត្យព្យាបាល ស្ត្រីដែលប្រឈមមុខនិងគ្រោះថ្នាក់ឆ្លងមេរោគអេដស៍ កាមរោគ នៅតាមចំណុចគោលដៅមួយចំនួនក្នុងរាជធានីភ្នំពេញ ។

| | កន្លែង/ តំបន់ | ចំនួនស្ត្រីដែលបានពិនិត្យខែកក្កដា | ចំនួនស្ត្រីដែលបានពិនិត្យខែសីហា | ចំនួនស្ត្រីដែលបានពិនិត្យខែកញ្ញា |
|---|---|---|---|---|
| 1 | បាសាក់ | 70 នាក់ | 24 នាក់ | 0 នាក់ |
| 2 | ព្រែកលាប | 152 នាក់ | 226 នាក់ | 184 នាក់ |
| 3 | ម៉ាស្សា | 139 នាក់ | 131 នាក់ | 134 នាក់ |
| 4 | Karoke/ Hotel | 202 នាក់ | 242 នាក់ | 195 នាក់ |

| | | | | |
|---|---|---|---|---|
| 5 | Srey Sras | 21 នាក់ | 61 នាក់ | 64 នាក់ |

**ឃ. សកម្មភាពបណ្តុះបណ្តាល និងចំប៉ុនចំណេះដឹង :**

- រៀបចំវគ្គសិក្ខាសាលា ស្តីអំពី STI Intensive Course for Lab Technician and Clinician ដែលមានសិក្ខាកាមចូលរួមចំនួន២០នាក់ មកពីខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ចាមសៀមរាប ព្រៃវែង ស្វាយរៀង និងអង្គការ ភ្សធ ឧបត្ថម្ភដោយ US-CDC
- ចូលរួមសំរបសំរួលវគ្គបណ្តុះបណ្តាលអ្នកបច្ចេកទេសមន្ទីរពិសោធន៏ ធ្វើតេស្តឈាមរកមេរោគអេដស៏ នៅមជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺអេដស៏ ។
- ចូលរួមវគ្គបណ្តុះបណ្តាលបំប៉នបន្ថែមស្តីពី ការគ្រប់គ្រង និងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា សំរាប់អ្នកផ្តល់សេវាបណ្តាញបន្ទប់ពិគ្រោះព្យាបាលជំងឺសញ្ញាព្រះអាទិត្យ នៅសណ្ឋាគារ Imperial ។
- មន្ត្រីគ្លីនិកជាតិ២រូប បានចូលរួម Fellowship Training in Cutaneos and Laser Surgery នៅទីក្រុងបាងកក ប្រទេសថៃ ។
- មន្ត្រីគ្លីនិកជាតិ២រូប បានចូលរួមសិក្ខាសាលាស្តីអំពី Update on Clinical Management of HIV/AIDS/STI នៅទីក្រុង Portsmouth ប្រទេសអង់គ្លេស ។
- មន្ត្រីគ្លីនិកជាតិ១រូប បានចូលរួម Training on Sexually Transmitted disease Laboratory នៅទីក្រុងបាងកក ប្រទេសថៃ ។
- មន្ត្រីគ្លីនិកជាតិ៤រូប បានចូលរួមសន្និសិទ្ធអន្តរជាតិ ស្តីអំពី "7th Asian Congress of Dermatology " នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ។

**សកម្មភាពផ្សេងៗ :**

- មន្ត្រី១រូប ចូលរួមក្នុងវគ្គសិក្ខាសាលា ស្តីពី វិជ្ជាសង្គ្រោះបឋម និងបន្ទប់ពិគ្រោះព្យាបាលជំងឺព្រះអាទិត្យ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។
- ចុះអភិបាល និងវាយតំលៃសកម្មភាពមន្ទីរពិសោធន៏ នៅគ្លីនិកកាមរោគ ខេត្តកោះកុង ក្រុងព្រះសីហនុ

**សកម្មភាពនៅថ្នាក់ខេត្ត :**

- រៀបចំវគ្គបណ្តុះបណ្តាល និង បំប៉ន ស្តីពីការគ្រប់គ្រង និងថែទាំជំងឺកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា សំរាប់មន្ត្រី មណ្ឌលសុខភាព ។

| | Provinces | Refresher training for HCs |
|---|---|---|
| 1 | កែប | ១៩ នាក់ |

| | | |
|---|---|---|
| 2 | កំពង់ស្ពឺ | ២៥ នាក់ |
| 3 | ក្រចេះ | ៤៣ នាក់ |
| 4 | ពោធិសាត់ | ៣០ នាក់ |
| 5 | ស្ទឹងត្រែង | ១៨ នាក់ |
| 6 | កំពង់ចាម | |
| 7 | ព្រះវិហារ | ១៥ នាក់ |
| 8 | ក្រុងព្រះសីហនុ | ៣៣ នាក់ |

- រៀបចំកិច្ចប្រជុំសំរបសំរួល ស្តីពីការគ្រប់គ្រង និងថែទាំជំងឺកាមរោគ

| | ខេត្ត | ចំនួនអ្នកចូលរួម |
|---|---|---|
| 1 | កំពត | |
| 2 | កំពង់ធំ | ១០ នាក់ |
| 3 | កោះកុង | ៧ នាក់ |
| 4 | ប៉ៃលិន | ៧ នាក់ |
| 5 | ស្វាយរៀង | ៧ នាក់ |
| 6 | បាត់ដំបង | ២៨ នាក់ |
| 7 | ព្រះវិហារ | ១៥ នាក់ |
| 8 | ព្រៃវែង | ១២ នាក់ |

- ចុះពិនិត្យ និងព្យាបាលជំងឺកាមរោគចល័ត ជារៀងរាល់ខែ ដល់នារីរកស៊ីផ្លូវភេទដោយផ្ទាល់ និងប្រយោល នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ, ព្រៃវែង ស្រុកបាវិត ខេត្តស្វាយរៀង និងស្រុកក្រគរ ខេត្តពោធិសាត់ ។
- ចុះអភិបាលលើការងារគ្រប់គ្រង និងការផ្តល់សេវាថែទាំជំងឺកាមរោគ ពីថ្នាក់ខេត្ត ទៅស្រុកប្រតិបត្តិ និងពីស្រុកប្រតិបត្តិទៅ មណ្ឌលសុខភាពដែលមាផ្តល់សេវាថែទាំជំងឺកាមរោគ ។

| Province | # Supervisions from PAO to OD(sites) | # Supervisions from OD to HCs (sites) |
|---|---|---|
| 1BMC | 4trips (4 ODs) | NA |
| 2BTB | 5trips (5 ODs) | 39trips (39 HCs) |
| 3KCM | 10trips (10 ODs) | NA |
| 4KCN | 2trips (2 ODs) | 5trips (5 HCs) |
| 5KTM | 3trips (3 ODs) | 17trips (17 ODs) |
| 6KDL | 2trips (2sites) | NA |
| 7KEP | | 7trips (7 sites) |

| | | | |
|---|---|---|---|
| 8 | KSP | 3trips (3 ODs) | 25trips (15 sites) |
| 9 | KPT | 4trips (4 ODs) | 24trips (36 sites) |
| 10 | KHK | 2trips (2 ODs) | 10trips (10 sites) |
| 11 | KRT | 2trips (2 ODs) | 42trips (21 sites) |
| 12 | OMC | NA | NA |
| 13 | MDK | | 1trip (1 site) |
| 14 | PNP | NA | NA |
| 15 | PLN | | 4trips (4 sites) |
| 16 | PST | 2trips (2 ODs) | 10trips (13 sites) |
| 17 | PVG | 6trips (6 ODs) | 34trips (34 sites) |
| 18 | RTK | | NA |
| 19 | SRP | 3trips (3 ODs) | 6trips (6 sites) |
| 20 | SHV | NA | NA |
| 21 | SVR | 3trips (3 ODs) | 20trips (20 sites) |
| 22 | TKV | 3trips (3 ODs) | NA |

## ២. កញ្ចប់សំរាប់ថែទាំ និងព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

### ២.១ ការថែទាំអ្នកជំងឺអេដស៍នៅក្នុងមន្ទីរពេទ្យ :

#### ក. ការរៀបរៀងឯកសារ និងគោលការណ៍ណែនាំ :

ដើម្បីឱ្យការអនុវត្តកម្មវិធីនេះកាន់តែមានភាពប្រសើរ មន្ត្រីផ្នែកថែទាំជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំជាមួយ ក្រុមការងារបច្ចេកទេស:

- រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំង នឹងមេរោគអេដស៍ លើកុមារ

#### ខ. ការប្រជុំ

- រៀបចំប្រជុំក្រុមការងារបច្ចេកទេស ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំង នឹងមេរោគអេដស៍ លើកុមារ។ចូលរួមកិច្ចប្រជុំ 3rd meeting of Steering Committee Europaid Project

#### គ. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា :

- រៀបចំវគ្គសិក្ខាសាលា ស្តីពីផ្លាស់ប្តូរបទពិសោធន៍ការថែទាំ និងព្យាបាលបន្តដល់អ្នកជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ នៅក្រុងព្រះសីហនុ ដែលមានអ្នកចូលរួម ចំនួន៧៥ នាក់ មកពីមន្ទីរពេទ្យនៅខេត្តបាត់ដំបង, ខេត្តកំពង់ចាម, សៀមរាប, បន្ទាយមានជ័យ, តាកែវ, កោះកុង, ពោធិសាត់, ក្រុងព្រះសីហនុ, អ្នកលឿង, ស្វាយរៀង, កំពង់ត្រាច, កណ្តាល មន្ទីរពេទ្យកាល់ម៉ែត មណ្ឌលនៃក្តីសង្ឃឹម និងគ្លីនិកសុខភាពសង្គម /មជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ *(របាយការណ៍នៅក្នុងឧបសម្ព័ន្ធទី២)*។

- រៀបចំវគ្គបណ្តុះបណ្តាល ចំនួន២វគ្គ រយៈពេល៣អាទិត្យ ស្តីពីការផ្តល់ប្រឹក្សាពីឱសថប្រឆាំងមេរោគអេដស៍ សំរាប់គិលានុប្បដ្ឋាក-យិកា បានចំនួន៥៥នាក់។
- រៀបចំវគ្គបណ្តុះបណ្តាល រយៈពេល៣អាទិត្យ ស្តីពីការគ្រប់គ្រងឱសថ និងសំភារៈបរិក្ខា សំរាប់អ្នកគ្រប់គ្រងឱសថស្ថានមន្ទីរពេទ្យបង្អែក/សេវាថែទាំ-ព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ជំនាន់ទី២, ចំនួន ២៨នាក់មកពីមន្ទីរពេទ្យបង្អែកនៃខេត្ត-ក្រុង ដូចជា ខេត្តកំពង់ឆ្នាំង តាកែវ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ព្រៃវែង ស្វាយរៀង កោះកុង ពោធិសាត់ កំពង់ចាម ក្រុងព្រះសីហនុ កំពត កំពង់ធំ កណ្តាល និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀត។
- ចុះជួយផ្តល់បច្ចេកទេសក្នុងការរៀបចំការរាងរសេវាថែទាំ-ព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅស្រុកគីរីវង្ស ខេត្តតាកែវ, ខេត្តកំពង់ស្ពឺ។
- សំរបសំរួលក្នុងការធ្វើកមសិក្សារបស់មន្ត្រីដែលបំរើការងារនៅផ្នែក ថែទាំ-ព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មកពីខេត្តសៀមរាប, ព្រៃវែង, នៅមន្ទីរពេទ្យជាតិ នៅរាជធានីភ្នំពេញ។
- ចូលរួមជាគណៈអធិបតីក្នុងពិធីសម្ពោធអាគារផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម សេវាថែទាំ-ព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។

**សិក្ខាសាលា និងកិច្ចប្រជុំក្រៅប្រទេស :**

- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅវិទ្យាស្ថានវេជ្ជសាស្ត្រតំបន់ត្រូពិច ទីក្រុង អង់វែរ ប្រទេសបែលហ្សិក។
- ទស្សនកិច្ច ផ្លាស់ប្តូរបទពិសោធន៍ការងារ លើការគ្រប់គ្រងថែទាំ និងព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ ដល់កុមារ នៅប្រទេសថៃ ដែលមានអ្នកចូលរួមចំនួន១៤នាក់ មកពីខេត្តតាកែវ, បាត់ដំបង, កោះកុង, សៀមរាប, ស្វាយរៀង, ក្រុងព្រះសីហនុ, ពោធិសាត់, កណ្តាល, និងមន្ទីរពេទ្យកុមារជាតិ។

**សកម្មភាពនៅថ្នាក់ខេត្ត :**

- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការជាសកល ដល់មន្ត្រីសុខាភិបាល

| | ខេត្ត | ចំនួនអ្នកចូលរួម |
|---|---|---|
| 1 | កំពត | ២៤ នាក់ |
| 2 | ក្រចេះ | ១៦ នាក់ |
| 3 | ឧត្តរមានជ័យ | ១៥ នាក់ |
| 4 | ព្រះវិហារ | ៣០ នាក់ |

| 5 | បន្ទាយមានជ័យ | ២៥ នាក់ |
|---|---|---|

- មានអ្នកជំងឺអេដស៍សំរាកពេទ្យចំនួន ៣៦៦ នាក់ និងក្នុងនោះមានអ្នកជំងឺ ៣២៥ នាក់ដែលបានទទួលអាហារឧបត្ថម្ភ (នៅខេត្តបន្ទាយមានជ័យ)
- ផ្តត់ផ្គង់ដល់ការធ្វើបុណ្យសពដល់អ្នជំងឺអេដស៍ដែលក្រីក្រ សំរាកក្នុងមន្ទីរពេទ្យ ចំនួន ២៩នាក់ នៅក្នុងត្រីមាសទី ៣ នេះ នៅខេត្តបន្ទាយមានជ័យ ។ចុះអភិបាលការថែទាំអ្នកជំងឺអេដស៍ នៅតាមមន្ទីរពេទ្យ (ខេត្តកោះកុង ស្វាយរៀង បន្ទាយមានជ័យ សៀមរាប និងខេត្តព្រៃវែង) ។
- ប្រជុំគណៈកមការថែទាំ និងព្យាបាលបន្ត ជារៀងរាល់ខែ
- ប្រជុំ MMM

| | | # of MMM meeting | # of PLHA attended | # of CoC meeting | # of participants | # OIs team meeting | # of participants |
|---|---|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | 6 | 660 | 4 | 96 | | |
| 2 | បាត់ដំបង | | | 2 | 88 | | |
| 3 | កំពង់ចាម | 6 | 665 | 6 | 180 | | |
| 4 | កំពង់ឆ្នាំង | 3 | 340 | 3 | 80 | 3 | 33 |
| 4 | កំពង់ស្ពឺ | 3 | 420 | 3 | 57 | | |
| 5 | កំពត | 3 | 593 | 6 | 118 | 3 | 33 |
| | កំពង់ធំ | 2 | 152 | 3 | 63 | | |
| 6 | កោះកុង | 3 | 403 | 3 | 73 | 3 | 27 |
| 7 | ពោធិសាត់ | 3 | 602 | 3 | 23 | | |
| | ប៉ៃលិន | 3 | 185 | 2 | 20 | | |
| 8 | ព្រៃវែង | 6 | 678 | 4 | 60 | 6 | 57 |
| 9 | សៀមរាប | 6 | NA | 6 | NA | | |
| 10 | ក្រុងព្រះសីហនុ | 2 | 200 | 2 | 50 | | |
| 11 | ស្វាយរៀង | 6 | 369 | 6 | 67 | 3 | 30 |
| 12 | តាកែវ | 2 | 296 | 3 | NA | | |

* KPT has 2 CoC sites (KPT and Kampong Trach OD)
* KCM has 3 CoC sites (KCM, Tbong Khmom, & Memut OD)
* PVG has 2 CoC sites (Kampong Leav & Neak Loeung OD)

* SRP has 2 CoC sites (SRP and Sot NikumOD)
* SVR has 2 CoC sites (Svay Rieng & Romeas Hek OD)

- ចំនួនអ្នកជំងឺអេដស៍ដែលបានទទួលការព្យាបាលដោយឱសថឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ នៅតាមបណ្តាមន្ទីរពេទ្យ ***(សូមមើលរបាយការណ៍នៅក្នុងឧបសម្ព័ន្ធទី១)***

**សកម្មភាពរបេង / អេដស៍** :

| | # of TB case refer to VCCT | #of Refuse | # of HIV (+) | % | # of HIV (+) refer to TB | #of Refuse | # of TB (+) | % |
|---|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | 349 | 44 | 11 | 4% | 360 | 142 | 46 | 21% |

- រៀបចំកិច្ចប្រជុំរបេង/អេដស៍ ដែលមានអ្នកចូលរួម៣១នាក់ មកពីកម្មវិធីអេដស៍, អ្នកសំរបសំរួលកម្មវិធីរបេង អេដស៍ អ្នកសំរបសំរួលកម្មវិធីអេដស៍ស្រុក និងតំណាងអង្គការ US-CDC (ខេត្តបន្ទាយមានជ័យ)
- ចុះអភិបាលលើការងារព្យាបាល និងថែទាំ របេង អេដស៍ នៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព ដែលមាន កម្មវិធីរបេង អេដស៍ (ខេត្តបន្ទាយមានជ័យ)
- ចុះអភិបាលលើការងារកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន នៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព ដែលមានកម្មវិធីកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន (ខេត្តបន្ទាយមានជ័យ)
- រៀបចំវគ្គសិក្ខាសាលាបំប៉ន រយៈពេល៣ថ្ងៃ ស្តីពីការផ្តល់ប្រឹក្សា ដល់មន្ត្រីកម្មវិធីកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូនចំនួន១២រូបមកពី មន្ទីរពេទ្យ និងមណ្ឌលសុខភាព ដែលមានកម្មវិធីកាត់បន្ថយការចំលងមេរោគ អេដស៍ពីម្តាយទៅកូន (ខេត្តបន្ទាយមានជ័យ) ។

## ២.២ ការថែទាំអ្នកជំងឺអេដស៍ តាមផ្ទះ និងតាមសហគមន៍ :

**សកម្មភាពនៅថ្នាក់ជាតិ :**

**ក. ការរៀបរៀងឯកសារ និងគោលការណ៍ណែនាំ :**

ដើម្បីឱ្យការអនុវត្តកម្មវិធីនេះកាន់តែមានភាពប្រសើរ មន្ត្រីផ្នែកថែទាំជំងឺអេដស៍តាមផ្ទះ បានរៀបចំ និងបោះពុម្ពសៀវភៅអាសយដ្ឋាន សេវាកម្ម ស្តីពីផ្នែកថែទាំជំងឺអេដស៍តាមផ្ទះ និងក្នុងសហគមន៍ - បណ្តាញអ្នកផ្ទុកមេរោគអេដស៍ ។

**ខ. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា :**

- ចូលរួមកិច្ចប្រជុំសំរបសំរួល នៃបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ នៅខេត្តសៀមរាប រៀបចំដោយ CPN+ ។

- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការនិងថែទាំជំងឺអេដស៍ នៅប្រទេសថៃ ។

**សកម្មភាពនៅថ្នាក់ខេត្ត :**

- រៀបចំកិច្ចប្រជុំ បណ្តាញក្រុមថែទាំអ្នក ជំងឺអេដស៍ តាមផ្ទះនិងសហគមន៍ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ដោះស្រាយបញ្ហាផ្សេងៗ និងរៀបចំផែនការ អនុវត្តន៍កម្មវិធីបន្ត ។
- ការផ្គត់ផ្គង់កញ្ចប់ថ្នាំ សំរាប់ថែរក្សាសុខភាព Home Care Kit អោយដល់អ្នកជំងឺអេដស៍ក្រីក្រ ៣០១នាក់ នៅក្នុងត្រីមាសទី៣ នៅខេត្តបន្ទាយមានជ័យ ។
- ស្វែងរក និងផ្តល់ការគាំទ្រលើកទឹកចិត្ត និងព្យាបាលដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺនៅតាមផ្ទះនិងតាមសហគមន៍ ***(សូមមើលរបាយការណ៍នៅក្នុងឧបសម្ព័ន្ធទី១)***
- ចុះអភិបាល ការងារក្រុមថែទាំអ្នក ជំងឺអេដស៍ តាមផ្ទះនិងសហគមន៍ ។

| | | # network meeting | # paticipants | # of supervision | # Sites visits |
|---|---|---|---|---|---|
| 1 | BMC | | | 12 | 12 |
| 2 | KCM | | | 1 | 1 |
| 3 | KCN | 1 | 25 | 2 | 2 |
| 4 | KDL | 1 | 38 | 2 | 3 |
| 5 | KSP | 1 | 20 | 12 | 12 |
| 6 | KPT | | | 7 | 4 |
| 7 | PLN | 1 | 20 | 4 | 2 |
| 8 | PVG | | | 14 | 10 |
| 9 | SRP | 1 | 42 | 2 | 2 |
| 10 | KTM | | | 5 | 4 |

### ២.៣ សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់

**ក. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា :**

- រៀបចំវគ្គសិក្ខាសាលា ស្តីពីការផ្តល់ប្រឹក្សាអំពីមេរោគអេដស៍ និងជំងឺអេដស៍ ចំនួន២វគ្គ ដល់មន្ត្រីផ្តល់ប្រឹក្សា ចំនួន ៤៥នាក់ មកពីខេត្ត ខេត្តកំពត សៀមរាប បាត់ដំបង, កំពង់ចាម, តាកែវ, កោះកុង, ពោធិសាត់, ក្រុងព្រះសីហនុ, ព្រៃវែង, ស្វាយរៀង, បន្ទាយមានជ័យ, កណ្តាល, ភ្នំពេញ, កំពង់ឆ្នាំង, កំពង់ស្ពឺ, ឧត្តរមានជ័យ, ព្រះវិហារ, ស្ទឹងត្រែង, ក្រចេះ ។
- រៀបចំវគ្គសិក្ខាសាលា ស្តីពីការគ្រប់គ្រងទិន្នន័យសំរាប់មណ្ឌលផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ចំនួន២វគ្គ ដែលមានអ្នកចូលរួម៣៧នាក់ មកពីខេត្តកំពត, ភ្នំពេញ, កំពង់ចាម, តាកែវ, ក្រុងព្រះសីហនុ, ព្រៃវែង, ស្វាយរៀង, កណ្តាល, កំពង់ឆ្នាំង, កំពង់ស្ពឺ, ស្ទឹងត្រែង, កោះកុង ។
- រៀបចំវគ្គសិក្ខាសាលា ស្តីពីការធ្វើតេស្តមន្ទីរពិសោធន៍សំរាប់មណ្ឌលផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ចំនួន២វគ្គ ដែលមានអ្នកចូលរួម៣៧នាក់ ។

**ត. ការងារអភិបាល :**

- មន្ត្រីផ្នែកថែទាំជងឺអេដស៍ បានចុះអភិបាលការងារលើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម ការថែទាំអ្នកជំងឺអេដស៍នៅក្នុងមន្ទីរពេទ្យ ថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងកម្មវិធីថែទាំនិងព្យាបាលបន្ត នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួនដូចជា: កំពង់ចាម (ស្រុកប្រតិបត្តិក្រូចឆ្មារ, មេមត់ និងចំការលើ) ក្រចេះ ស្ទឹងត្រែង កណ្តាល តាកែវ (ស្រុកប្រតិបត្តិគីរីវង្ស និងអង្គរកា) កំពត ព្រះវិហារ កំពង់ធំ សៀមរាប ភ្នំពេញ រតនគីរី ស្វាយរៀង កោះកុង និងព្រៃវែង។។
- ផ្គត់ផ្គង់និងធ្វើការបែងចែកសំភារ: Reagent ដល់គ្រប់សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយសគ្រ័ចិត្ត និងរក្សា ការសំងាត់។

**សកម្មភាពនៅថ្នាក់ខេត្ត :**

- ចុះអភិបាលការងារលើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមការថែទាំអ្នកជំងឺអេដស៍នៅក្នុងមន្ទីរពេទ្យ ថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងកម្មវិធីថែទាំនិងព្យាបាលបន្ត នៅស្រុកប្រតិបត្តិ។
- កិច្ចប្រជុំប្រចាំត្រីមាស របស់ក្រុមអ្នកផ្តល់ប្រឹក្សា ផ្នែកមន្ទីរពិសោធន៍ ។
- ចំនួនអតិថិជនដែលមកទទួលសេវា ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម រកមេរោគអេដស៍ ***(សូមមើលរបាយការណ៍ នៅក្នុងឧបសម្ព័ន្ធ ទី១)***.

*Table 20:* VCCT Activities

| | Province | # network meeting | # Participants | # of supervision | # Sites visits |
|---|---|---|---|---|---|
| | BMC | 2 | 42p | 5 | 5 |
| 1 | BTB | 1 | NA | 2 | 2 |
| 2 | KCM | | | | |
| 3 | KCN | 1 | 12p | | |
| 4 | KEP | | | 1 | 1 |
| 5 | KPT | 1 | 14 | 4 | 4 |
| 6 | KRT | 3 | 15 | | |
| 7 | PVG | 1 | 8 | 5 | 5 |
| 8 | SRP | 1 | 23 | 3 | 3 |
| 9 | TKV | 1 | 8 | | |
| 10 | SVR | | | 2 | 2 |
| 11 | KSP | | | 2 | 2 |

## ៧. កញ្ចប់អង្កេត និងស្រាវជ្រាវ :

### ៧.១ ការអង្កេតតាមដាន :

**ក. ការអង្កេតរកអត្រាប្រេវ៉ាឡង់ជំងឺកាមរោគ :**

- ចុះប្រមូលទិន្នន័យ ស្ដីពីការអង្កេតតាមដានរកអត្រា ប្រេវ៉ាឡង់ជំងឺកាមរោគឆ្នាំ២០០៤ លើក្រុមប្រឈមមុខខ្ពស់ ដូចជា នារីរកស៊ីផ្លូវភេទដោយផ្ទាល់ ដោយប្រយោល បុរសរួមភេទជាមួយបុរស និងប៉ូលីស នៅខេត្តកោះកុង និក្រុងព្រះសីហនុ។
- បញ្ចប់ការបញ្ចូលទិន្នន័យលើកទី១ ស្ដីពីការអង្កេតតាមដានរកអត្រាប្រេវ៉ាឡង់ជំងឺកាមរោគឆ្នាំ២០០៤ និងរៀបចំតារាងសំនួរនៃការបញ្ចូលនេះទៅឱ្យវិទ្យាស្ថានជាតិសុខភាពសាធារណៈ ដើម្បីធ្វើការបញ្ចូលទិន្នន័យលើកទី២។

**ខ. ការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ :**

- ចូលរួមកិច្ចប្រជុំ ដើម្បីរៀបចំពិធីសារ សំរាប់ការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ឆ្នាំ ២០០៦
- ស្រង់ស្ថិតិចំនួននារីរកស៊ីផ្លូវភេទ និងចំនួនស្ត្រីមេផ្ទះដែលមកពិនិត្យផ្ទៃពោះ នៅតាមមន្ទលសុខភាព និងមន្ទីរពេទ្យបង្អែក តាមបណ្ដាខេត្ត-ក្រុងទាំង ២៤។

**គ. ការអង្កេតអកម :**

- ចុះប្រមូលទិន្នន័យ ស្ដីពីការអង្កេតអកម នៅខេត្តសៀមរាប បន្ទាយមានជ័យ កំពត តាកែវ ក្រុងព្រះសីហនុ ព្រះវិហារ និងខេត្តកោះកុង។

## ៣.២ ការងារស្រាវជ្រាវទាក់ទងទៅនឹងជំងឺអេដស៍ កាមរោគ

**ក. កិច្ចប្រជុំ/សិក្ខាសាលា :**

- ចូលរួមប្រជុំវេទិកាសិក្សាស្រាវជ្រាវទៅលើការថែទាំសុខភាពរបស់សហគមន៍ ជាមួយតំណាងអ្នកផ្ទុកមេរោគអេដស៍ ។
- រៀបចំកែសំរួលរបាយការណ៍ ការអង្កេតលើចំណេះដឹងពីជំងឺអេដស៍ (KAP Survey)
- រៀបបញ្ចូលទិន្នន័យរបស់គ្លីនិកសុខភាពសង្គមផ្ញើរទៅ TREAT ASIA
- រៀបចំ Develop Satisfactory Survey Protocol

**ខ. សកម្មភាពក្រៅប្រទេស :**

- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី Principle of HIV/AIDS STI Research នៅទីក្រុង Seattle ប្រទេសអាមេរិក។
- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី Field Epidemiology Training Program នៅទីក្រុងបាងកក ប្រទេសថៃ។

- ចូលរួមសន្និសិទ្ធ ស្តីពីជំងឺអេដស៏ នៅទីក្រុងកូបេ ប្រទេសជប៉ុន ។
- ចូលរួមសន្ទសិទ្ធ ស្តីពីជំងឺកាមរោគ នៅប្រទេសបែលហ្សិក។

## ៤. កញ្ចប់គ្រប់គ្រង :

### ៤.១ ផែនការ គ្រប់គ្រង និងសំរបសំរួល :

**សកម្មភាពនៅថ្នាក់ជាតិ :**

- រៀបចំកិច្ចប្រជុំសំរបសំរួល ដែលមានការចូលរួមពី២៤ខេត្ត-ក្រុង អង្គការជាដៃគូ និងអង្គភាពផ្សេងៗ ដូចជាមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក នាយកដ្ឋាននានានៃក្រសួងសុខាភិបាល ។ គោលបំណងនៃកិច្ចប្រជុំនេះ គឺៈ
  - ពិនិត្យមើលនូវសមិទ្ធិផលដែលសំរេចបាន ក្នុងត្រីមាសទី១ និងទី២ ឆ្នាំ ២០០៥
  - ពិនិត្យមើលនូវគំរោងផែនការ និងប្រភពថវិកាដែលមាន សំរាប់ពីខែកក្កដា ដល់ខែធ្នូ ២០០៥
  - បញ្ហាផ្សេងៗដែលជួបប្រទះក្នុងការអនុវត្តសកម្មភាព របស់ខេត្តក្រុងទាំង ២៤
  - ការគ្រប់គ្រងថវិកា និងបញ្ហាផ្សេងៗ
  - រៀបចំគំរោងផែនការត្រីមាសទី៤ ២០០៥ ***(សូមមើលរបាយការណ៍នៅ ឧបសម្ពន្ធ័ ទី ២)***
- រៀបចំផែនការសកម្មភាព ប្រចាំត្រីមាសទី៣ និងទី៤ ឆ្នាំ២០០៥ របស់មជ្ឈមណ្ឌលជាតិ និងខេត្ត-ក្រុង។

## ៩. សកម្មភាពផ្សេងៗ :

- បានចុះអភិបាលលើសកម្មភាព ការងាររបស់កម្មវិធីអេដស៏ នៅខេត្តកំពង់ចាម តាកែវ ស្វាយរៀង ប៉ៃលិន កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង ក្រុងព្រះសីហនុ ស្ទឹងត្រែង ក្រចេះ ព្រះវិហារ និង កណ្តាល

## ក. សកម្មភាពនៅថ្នាក់ខេត្ត :

- ទស្សនកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៏ការងារលើការគ្រប់គ្រង កម្មវិធីអេដស៏នៅខេត្តសៀមរាប របស់កម្មវិធីអេដស៏ខេត្តកណ្តាល។
- ទស្សនកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៏ការងារលើការគ្រប់គ្រង កម្មវិធីអេដស៏នៅខេត្តសាកែវ និងឈុនបូរី ប្រទេសថៃ របស់កម្មវិធីអេដស៏ខេត្តបន្ទាយមានជ័យ។

- រៀបចំកិច្ចប្រជុំសំរបសំរួល ជាមួយដៃគូការងារ និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារអេដស៍ នៅក្នុងខេត្ត ដើម្បីស្វែងរកបញ្ហាផ្សេងៗ និងដំណោះស្រាយ រាល់បញ្ហាដែលកើតមានឡើង ដើម្បីធ្វើឱ្យការអនុវត្តកម្មវិធីរឹតតែល្អ ដូចជាខេត្តខាងក្រោម:

| | ខេត្ត | ចំនួនអ្នកចូលរួម |
|---|---|---|
| 1 | កំពត | 21p |
| 2 | កោះកុង | 20p |
| 3 | ក្រចេះ | 37p |
| 4 | កំពង់ធំ | 23p |
| 5 | ពោធិសាត់ | |
| 6 | ព្រៃវែង | 33p |
| 7 | កំពង់ចាម | 28p |
| 8 | ប៉ៃលិន | 25p |
| 9 | តាកែវ | 9p & NGOs |
| 10 | ស្ទឹងត្រែង | 12p |
| 11 | មណ្ឌលគិរី | NA |
| 12 | កណ្តាល | 38p |
| 13 | កំពង់ឆ្នាំង | 65p |
| 14 | សៀមរាប | 48p |
| 15 | ក្រុងព្រះសីហនុ | 23p |
| 16 | ស្វាយរៀង | 20p |
| 17 | កំពង់ស្ពឺ | NA |
| 18 | បន្ទាយមានជ័យ | 41p |

## ៤.២ ការតាមដានត្រួតពិនិត្យ របាយការណ៍ និងវាយតំលៃកម្មវិធី :

**សកម្មភាពនៅថ្នាក់ជាតិ :**

- រៀបចំវគ្គសិក្ខាសាលា ស្តីពីការរៀបចំផែនការ ក្រោមគំរោងមូលនិធិសកលវគ្គទី២ នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម ដោយមានការចូលរួមពីប្រធានមន្ទីសុខាភិបាល ប្រធានកមវិធីអេដស៍ និងគណនេយ្យគំរោងមកពីខេត្ត-ក្រុងទាំង៦និងផ្នែកផ្សេងៗនៃមជ្ឈមណ្ឌលជាតិ ។***(សូមមើលរបាយការណ៍នៅឧបសម្ពន្ធ័ ទី ២)***
- មន្ត្រីផ្នែកតាមដានត្រួតពិនិត្យ វាយតំលៃ និងរបាយការណ៍ នៃការិយាល័យបច្ចេកទេស រួមជាមួយមន្ត្រីផ្នែកផែនការ និងមន្ត្រីផ្នែកគណនេយ្យ បានចុះអភិបាលលើសកមភាព ការងាររបស់កមវិធីអេដស៍ នៅខេត្តកំពង់ចាម ប៉ៃលិន ពោធិសាត់ បាត់ដំបង តាកែវ ក្រុងព្រះសីហនុ កណ្តាល ។
- រៀបចំរបាយការណ៍ប្រចាំត្រីមាសទី៣ ជាភាសាខ្មែរនិងភាសាអង់គ្លេស ស្តីពីសកមភាពបង្ការ និងថែទាំជំងឺអេដស៍ របស់មជ្ឈមណ្ឌលជាតិ និងខេត្ត-ក្រុងទាំង២៤ និងបានធ្វើការបែងចែកទៅដល់មន្ទីរនិងអង្គការ នានាដែលពាក់ពន្ធ័ ។
- រៀបចំឱ្យមានប្រពន្ធ័របាយការណ៍គ្រប់គ្រងលទ្ធផលការបញ្ចូលទិន្នន័យ និងការវិភាគ ទិន្នន័យ ។

**សកមភាពនៅថ្នាក់ខេត្ត :**

- រៀបចំរបាយការណ៍ប្រចាំខែ ស្តីពីសកមភាពបង្ការ និង ថែទាំជំងឺអេដស៍ ផ្ញើរមកមជ្ឈមណ្ឌលជាតិ ។
- ចុះអភិបាលលើ ការងារគ្រប់គ្រងកមវិធីអេដស៍ កាមរោគ នៅថ្នាក់ស្រុកប្រតិបត្តិ ។
- រៀបចំវគ្គសិក្ខាសាលា ស្តីពីការគ្រប់គ្រង ការតាមដាន និងវាយតំលៃ ដល់មន្ត្រីសំរបសំរួលនៅថ្នាក់ស្រុកប្រតិបត្តិ និងមន្ត្រីកមវិធីអេដស៍ខេត្ត ( ខេត្តកំពង់ចាម) ។

